**ភ្នំពេញ ប្រទេសកម្ពុជា**
**ថ្ងៃ ព្រហស្បតិ៍ ទី ១៥ ខែ កក្កដា ឆ្នាំ ២០១០**

# សេចក្តីជូនដំណឹង

## អង្គការពលកម្មអន្តរជាតិ ចេញផ្សាយរបាយការណ៍សិក្សាពីអ្នកបម្រើសេវាផ្លូវភេទដោយប្រយោលដែលចេញពីឧស្សាហកម្មកាត់ដេរ

អង្គការពលកម្មអន្តរជាតិបានចេញផ្សាយនូវរបាយការណ៍សិក្សាបែបគុណវិស័យតូចមួយទៅលើស្ត្រីដែលចាកចេញពីការងារក្នុងឧស្សាហកម្មកាត់ដេរ អំឡុងពេលវិបត្តិសេដ្ឋកិច្ចដើម្បីធ្វើការនៅក្នុងវិស័យកម្សាន្តសប្បាយ។ ការសិក្សានេះធ្វើឡើងដើម្បីបង្កើនការយល់ដឹងនូវស្ថានភាពការងាររបស់ស្ត្រីទាំងនោះ រួមមានភាពងាយរងគ្រោះរបស់ពួកគេនឹងមេរោគអេដស៍ ជម្ងឺអេដស៍ ដើម្បីកំណត់នូវបញ្ហាក្នុងការផ្តល់ជំនួយឱ្យចំគោលដៅ ដើម្បីកាត់បន្ថយភាពរងគ្រោះដែលពាក់ព័ន្ធនឹងមេរោគអេដស៍។

ការសិក្សានេះ គឺធ្វើឡើងតាមការសម្ភាសបែបគុណវិស័យជាមួយអតីតកម្មការិនីចំនួន ១៦ នាក់ ដែលត្រូវបញ្ឈប់ពីការងារអំឡុងពេលនៃវិបត្តិសេដ្ឋកិច្ច ហើយដែលកំពុងបម្រើការងារនៅក្នុងវិស័យកម្សាន្តសប្បាយ ហើយបានផ្តល់នូវសេវាផ្លូវភេទនៅក្នុងទីក្រុងភ្នំពេញ ដើម្បីរកប្រាក់ចំណូលបន្ថែម។

ព័ត៌មានស៊ីជម្រៅដែលបានមកពីការសម្ភាស ត្រូវបានសំយោគចេញជាករណីសិក្សា ដែលផ្តោតលើបញ្ហាផ្សេងៗដូចជា ជីវភាពរស់នៅរបស់ស្ត្រីទាំងនោះកាលពីកុមារភាព បទពិសោធន៍របស់ពួកគេនៅក្នុងវិស័យកាត់ដេរ វិស័យកម្សាន្តសប្បាយ និងជាអ្នកបម្រើសេវាផ្លូវភេទដោយប្រយោល ការផ្លាស់ប្តូរនូវជីវភាពរស់នៅរបស់ពួកគេក្នុងអាជីពការងារផ្សេងៗគ្នា ផលប៉ះពាល់ដ៏គួរឱ្យកត់សម្គាល់នៃឱនភាពសេដ្ឋកិច្ច និងការប្រើប្រាស់ស្រោមអនាម័យជាមួយភ្ញៀវដែលជាអតិថិជន និងមិនមែនជាអតិថិជន។

អ្នកបម្រើសេវាទាំងអស់ ដែលត្រូវបានសម្ភាស បានឱ្យដឹងថាការសម្រេចចិត្តដើម្បីរកប្រាក់ចំណូលបន្ថែម ដោយការផ្តល់សេវាផ្លូវភេទបែបនេះ គឺដោយសារតែតម្រូវការថវិកា មានន័យថា ពួកគេត្រូវការប្រាក់ចំណូលបន្ថែម ដើម្បីចំណាយលើការស្នាក់នៅ ម្ហូបអាហារ និងថវិកាផ្ញើរទៅផ្ទះ។

ការសិក្សានេះក៏បានផ្តល់នូវអនុសាសន៍មួយចំនួន ដែលរួមមាន ការធ្វើយុទ្ធនាការដើម្បីបញ្ឈប់ការរំលោភបំពានមកលើអ្នកបម្រើការងារនៅក្នុងគ្រឹះស្ថានកម្សាន្តសប្បាយ ផលិតនិងផ្សព្វផ្សាយនូវសម្ភារៈអប់រំ ដើម្បីដោះស្រាយភាពងាយរងគ្រោះរបស់អ្នកបម្រើការងារក្នុងវិស័យកម្សាន្តសប្បាយ លើការរំលោភបំពាន និងបញ្ហាមេរោគអេដស៍ និងដើម្បីផ្តល់ព័ត៌មានដល់ពួកគេពីសិទ្ធិជាមូលដ្ឋានរបស់ខ្លួននៅកន្លែងធ្វើការ ដូចជា ប្រាក់ឈ្នួលសមរម្យ និងការចូលជាសមាជិកភាពរបស់សហជីព។ ដំណើរការផ្តល់អាជ្ញាប័ណ្ណសម្រាប់គ្រឹះស្ថានកម្សាន្តសប្បាយ ដែលដាក់បញ្ចូលនូវល័ក្ខខ័ណ្ឌជាមូលដ្ឋានដើម្បីឱ្យនិយោជកធ្វើការ

អនុវត្តតាម គួរត្រូវបានបង្កើត ក៏ដូចជាយន្តការត្រួតពិនិត្យត្រីភាគីដើម្បីពិនិត្យមើលលើល័ក្ខខ័ណ្ឌការងារនៅឯគ្រឹះស្ថានកម្សាន្តសប្បាយ។

ការសិក្សានេះត្រូវបានធ្វើឡើងដោយទីភ្នាក់អភិវឌ្ឍន៍របស់ប្រទេសអូស្ត្រាលី ដែលមានឈ្មោះថា Union Aid Abroad- APHEDA។ សេចក្តីសង្ខេបនៃការសិក្សាស្រាវជ្រាវនេះ (ដូចដែលបានភ្ជាប់ទៅជាមួយ) ក៏ដូចជា របាយការណ៍ពិស្តារ គឺអាចរកបាននៅលើគេហទំព័រ*គំរោងរោងចក្រកាន់តែប្រសើរនៅកម្ពុជា* នៃអង្គការពលកម្មអន្តរជាតិ www.betterfactories.org។

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងមក
លោក ប៊ុន យិញ
មន្ត្រីទំនាក់ទំនងព័ត៌មាន
ទូរស័ព្ទ ៖ ០១២ ៩០ ២៩ ៩០
អ៊ីម៉េល ៖ ying@ilo.org